# ការសំភាសន៍របស់លោកពូ កូវ វ៉ងឌី

**ក៖ អ្នកសំភាសន៍ឈ្មោះ ជុង សីហា ខ៖ អ្នកដែលត្រូវគេសំភាសន៍ឈ្មោះ កូវ វ៉ងឌី**

## សង្ខេបរបស់លោកពូ កូវ វ៉ងឌី

លោកពូកូវ វ៉ងឌីជាអ្នកខេត្តកំពង់ចាម ហើយដោយសារមានរដ្ឋប្រហារលន់នល់ ទំលាក់គ្រាប់បែកគាត់ក៏ទៅរស់នៅភ្នំពេញ ហើយបន្ទាប់ពីចូលរបបប៉ុល ពត គាត់ក៏ត្រលប់ទៅកំពង់ចាមហើយពួកប៉ុល ពតបានធ្វើបាបក្រុមគ្រួសារបានសម្លាប់មីង ពូ តាយាយបងប្អូនជីដូនមួយ ។ ហើយគាត់រស់នៅយ៉ាងលំបាកអត់មានអ្វីហូបស្គមខ្លាំង ហើយមានការលំបាកយ៉ាងខ្លាំង ហើយកំសត់ខ្លាំងបំផុត ហើយពេលខ្លះម្តាយបាននាំយកគាត់ទៅស្រែជាមួយដើម្បីបានបាយហូបខ្លះនៅពេលគេចែក ។ គាត់ពេលខ្លះគាត់ដើររើសឆ្អឹងត្រីហូបពីក្រោមផ្ទះគេ ហើយគាត់ថារស់មិនស្មើនឹងសត្វផង ដែលសត្វមានអីស៊ីតែពួកគាត់គ្មាន។សព្វថ្ងៃលោកពូជាគ្រូពេទ្យ ហើយគាត់រស់នៅជាមួយកូនប្រពន្ធរបស់គាត់ហើយបានស្គាល់ដំនឹងល្អរបស់ព្រះយេស៊ូវគ្រីស្ទគឺជួយអោយក្រុមគ្រួសារគាត់មានសុភមង្គល។

ក៖ អ៊ីចឹងថ្ងៃនេះខ្ញុំអរគុណពូឌីច្រើនមែនទែនដែលពូឌីបានអោយញ៉ុមធ្វើការសំភាសន៍ដែលសំនួរភាគច្រើនទាក់ទងហ្នឹងជីវិតរបស់លោកពូផ្ទាល់ហើយនឹងបទពិសោធន៍ជីវិតរបស់លោកពូ ហើយញ៉ុមដឹងថាកិច្ចការមួយនេះនឹងប្រទានពរជ័យដល់ក្រុមគ្រួសាររបស់លោកពូហើយព្រមទាំងកូនចៅលោកពូអោយគាត់បានសិក្សារនឹងដឹងពីជីវប្រវត្តិរបស់គាត់នៅថ្ងៃខាងមុខទៀតអញ្ចឹងទៅណាស់ពូ។ហើយការសំភាសន៍នេះត្រូវបានធ្វើឡើងនៅថ្ងៃទី០៥ ខែ០៩ ឆ្នាំ២០១៦ ហើយខ្ញុំឈ្មោះជុងសីហាជាអ្នកសំភាសន៍អ៊ីចឹងពូអាចជួយប្រាប់ឈ្មោះរបស់ពូនៅក្នុងអត្តសញ្ញាណបត្រ័ណាស់។

ខ៖ ក្នុងអត្តសញ្ញាបណ្ណ័របស់ខ្ញុំឈ្មោះកូវ វ៉ងឌីជួនកាលពេលអត្តសញ្ញាបណ្ណ័មុនដាក់កូវ វ៉ងឌី តែដល់ពេលអត្តសញ្ញាណបណ្ណ័ក្រោយញ៉ុមដាក់កូវ វ៉ងឌី។

ក៖ បាទហើយចុះក្នុងសៀវភៅកំណើត?

ខ៖ កូវ វ៉ងឌីដែរ។

ក៖ អ៊ីចឹងពូមានឈ្មោះហៅក្រៅទេ?

ខ៖អត់ទេអត់មានទេ។

ក៖ អត់មានទេ!!

ខ៖បាទ!!

ក៖អញ្ចឹងសំនួរបន្ទាប់ទៀតតើពូធ្លាប់រៀនភាសាអីគេផ្សេងក្រៅពីភាសាខ្មែរយើងដែរឬទេ?

ខ៖ ធ្លាប់រៀនភាសាបារាំង។

ក៖ ពូរៀនចប់ថ្នាក់ទីប៉ុន្មានដែរភាសាបារាំង?

ខ៖ ញ៉ុមអត់មានសាលាអីគេទេប៉ុន្តែញ៉ុមរៀនបានពីរឆ្នាំ បានពីរឆ្នាំ!!

ក៖ រៀនបានពីរឆ្នាំពូណោះ?

ខ៖ បាទ ញ៉ុមបានរៀនចេះអានរៀនចេះសរសេរណាស់ៗ!

ក៖បាទ!!

ខ៖ បានមួយចំនួនដែរ ហើយភាសាអង់គ្លេសហើយនឹងភាសាថៃ។

ក៖ អ៊ីចឹងបន្ទាប់មកទៀតពូជួយប្រាប់ទីកន្លែងកំណើត ទីកន្លែងកំនើតនឹងថ្ងៃខែរបស់លោកពូ?

ខ៖ ខ្ញុំបើនិយាយពេលខ្ញុំកើតខ្ញុំកើតនៅភ្នំពេញនៅឆ្នាំ១៩៧២ ខែ១២បាទ ។

ក៖ពូអត់ចាំថ្ងៃទេហ្ន៎?

ខ៖ ថ្ងៃសុក្រ។

ក៖ អ៊ិចឹងពូដោយសារតាមឆ្នាំសុរិយគតិឆ្នាំខ្មែរហោ!ពូកើតក្នុងចំនោមសត្វទាំង១២?

ខ៖ អើរកណ្តុរ!!

ក៖ អ៊ីចឹងឆ្នាំជូត !!

ខ៖បាទ!!

កះអ៊ីចឹងអរគុណច្រើនពូបាទ អ៊ីចឹងតើអើរអ៊ីចឹងពូអាចប្រាប់ខ្ញុំបន្តទៀតថាតើទីលំនៅរបស់លោកពូសព្វថ្ងៃនៅឯណា?

ខះ ខ្ញុំមករស់នៅភូមិអំពិលធំ ឃុំខ្វិតធំ ស្រុកព្រៃឈរ ខេត្តកំពង់ចាម។

កះ អ៊ីចឹងពូរស់នៅផ្ទះហ្នឹងប៉ុន្មានឆ្នាំហើយពូ?

ខះ ខ្ញុំនៅផ្ទះហ្នឹងតាំងពីឆ្នាំ១៩៩៩ ៩៨ (១៩៩៨)៩៩(១៩៩៩)ហ្នុំ!!៩៩ហ្នឹង(១៩៩៩)!!

កះ ១៩៩៩?

ខះ បាទ!!

កះ អ៊ីចឹងយូរដែរ?

ខះ យូរដែរ។

កះអ៊ីចឹងសំរាប់ពត៌មានបន្ទាប់ញ៉ុមចង់សួរទាក់ទងហ្នឹងអើរជីវិតពូដូចជាខាងឪពុកម្តាយអ៊ីចឹងហា៎ ពីពួកគាត់ទាំងពីរនាក់ហា៎ពូ!!

ខះបាទ!!

កះពូជួយប្រាប់ពីអាយុគាត់នឹងឈ្មោះរបស់ពួកគាត់?

ខះ អើរឪពុកខ្ញុំឈ្មោះកូវ រ៉េតហើយ ខ្ញុំមិនដឹងថាអាយុប៉ុន្មានទេតែគ្រាន់តែដឹងថាគាត់កើតឆ្នាំចហើយគាត់កើតមិនដឹងជាឆ្នាំ១៩០០ប៉ុន្មានដទេ ប៉ុន្តែឥលូវគាត់អាយុប្រហែលជាជិត៩០ហើយ!!បាទពួកគាត់នៅរស់ហា៎គាត់កើតឆ្នាំចម្តាយខ្ញុំឈ្មោះឡុត សារឹម ដូចជាគាត់កើតឆ្នាំ១៩៤០ជាងអីហ្នឹងប៉ុណ្ណឹងហា៎ ហើយម្តាយខ្ញុំគាត់កើតឆ្នំាម្សាញ់ឥឡូវគាត់អាយុ៧៦ហើយហ្នឹងហើយឥឡូវគាត់ចាស់ហើយ!!

កះ គាត់នៅរស់សព្វថ្ងៃ?

ខះ ហ្នឹងហើយគាត់នៅរស់ គាត់ស្នាក់នៅស្រុកកំណើតខាងខ្ញុំ ខាងខ្ញុំពេលនៅពីតូចៗហា៎ គាត់នៅឯងខាងភូមិព្រះធាតុប៉ុន្តែឃុំស្រុកតែមួយហើយគាត់នៅជាមួយប្អូនស្រី។

កះ អញ្ចឹងសំនួរបន្ទាប់ទៀតប្រហែលជាខ្ញុំចង់សាកសួរទាក់ទងទៅនឹងក្រុមគ្រួសាររបស់លោកពូផ្ទាល់វិញសំរាប់ប្រពន្ធរបស់លោកពូវិញមីងគាត់ឈ្មោះអីគេដែរ?

ខ៖ ហ៊ីគាត់ឈ្មោះម៉ូវ សម្កស្ស។

ក៖ គាត់អាយុប៉ុន្មានហើយលោកពូ?

ខ៖ គាត់៤០គត់។

ក៖ ពូមានចាំថ្ងៃខែឆ្នាំកំណើតរបស់គាត់ទេលោកពូ?

ខ៖ អត់ចាំ។

ក៖ ដឹងតែ៤០គត់ណោះលោកពូ?

ខ៖ហ៊ឺ!!

ក៖ហើយសំរាប់កូនរបស់លោកពូវិញពូមានកូនចំនួនប៉ុន្មាននាក់ដែរ?

ខ៖ ញ៉ុមមានកូន៤នាក់។

ក៖ ៤នាក់ អ៊ីចឹងពួកគាត់មានឈ្មោះអីគេខ្លះដែរលោកពូ?

ខ៖ កូនខ្ញុំទីមួយឈ្មោះ រ៉េត មុនី ទីពីរឈ្មោះរ៉េត សុខនីម រ៉េត មុនីហៅក្តែង  រ៉េត សុខនីមហៅរិត ហើយទីបីឈ្មោះរ៉េត ហាណាហៅស្រីម៉ៅ។

ក៖ អ៊ីចឹងពួកគាត់អាយុប៉ុន្មានពូអាចជួយប្រាប់តាមលំដាប់លំដោយ?

ខ៖ ពួកគាត់ កូនមុនីគាត់កើតឆ្នាំ១៩៩៩ ហើយសុខនីមវា១៣ឆ្នាំឆ្នាំហ្នឹងហើយ ដូចជាឆ្នាំ ១៣ឆ្នាំ ឆ្នាំហ្នឹងហើយ ហើយហាណាប្រហែលជា៩ឆ្នាំហើយបាទ៩ឆ្នាំ។

ក៖អរគុណពូ អរគុណច្រើនលោកពូដែលបានផ្តល់ពត៌មានលំអិតហើយហើយអ៊ីចឹងនៅអ្វីដែល បន្ទាប់ បន្ទាប់ពីការសិក្សារបស់ពូវិញតើពូអាចជួយរៀបរាប់ពីការសិក្សារបស់លោកពូតាំងពីតូច រហូតដល់ធំបានទេ?

ខ៖ ញ៉ុមកំរិតវប្បធមិញ៉ុមពេលប៉ុល ពត ពេលដាច់៧៩(១៩៧៩)ញ៉ុមបានរៀននៅក្នុងវត្តហើយ ញ៉ុមបានរៀនរហូតដល់ប្រលងឌីផ្លូមហើយប៉ុន្តែដោយភាពក្រីក្រញ៉ុមអត់អាចរៀនទៀតបាន ញ៉ុមចង់រៀនតទៀតដែរប៉ុន្តែញ៉ុមអត់មានសមត្ថភាពញ៉ុមក៏បញ្ឈប់ការសិក្សាហ្នឹងត្រឹមឌីផ្លូម ហ្នឹងទៅញ៉ុមប្រលងឌីផ្លូមឆ្នាំ១៩៨៥ហើយខ្ញុំអត់មានលទ្ធភាពសិក្សាបន្តទៅទៀតដោយសារ ជីវភាពខ្វះខាតហើយម៉ែឪអត់មានគាត់ក៏សំរេចចិត្តរុញញ៉ុមទៅបួសនៅក្នុងសាសនាព្រះពុទ្ធក៏

បានទៅបួសហើយបានទៅរៀននៅសាលាបាលីជាប់បានជាប់សាលាបាលីរងឆ្នាំ១៩៩៣ញ៉ុម បានប្រលងជាប់សាលាបាលីរង ហើយញ៉ុមបានហើយបន្ទាប់ពីខ្ញុំបានរៀនបានមួយរយៈមក សុខភាពខ្ញុំមិនអំណោយផលខ្ញុំបានហើយញ៉ុមក៏សឹកមក សឹកមកខ្ញុំក៏ទៅរៀនយកជំនាញគ្រូ ពេទ្យក្នុងភូមិស្រុករបស់ខ្ញុំអីចឹងទៅណាស់!!ដើម្បីជួយព្យាបាទអ្នកស្រុកតាមលទ្ធភាពដែល យើងអាចធ្វើទៅបានបាទ ។

ក៖ អូខេអរគុណច្រើនលោកពូ អញ្ចឹងអ្វីដែលញ៉ុមចង់សួរលោកពូទៅនឹងសំនួរបន្ទាប់ញ៉ុមចង់ សួរទាក់ទងទៅហ្នឹងប្រវត្តិការងាររបស់លោកពូតាំងពីតូចរហូតដល់ធំអ៊ិចឹងហាំតើលោកពូអាច ជួយប្រាប់?

ខ៖ ការងាររបស់ខ្ញុំដោយសារខ្ញុំជាកូនអ្នកអើរស្រែកូនអ្នកកសិករ ហើយពេលញ៉ុមធំដឹងក្ដីកាល ណាខ្ញុំជាកូនអ្នកកសិករ នៅពេលដែលដាច់ពីប៉ុល ពតមកយើងអត់មាននៅសេសសល់ស្អីគេ ទេពេលនៅកសិករពីដើមនៅសល់មានដីមានធ្លីអីច្រើនដល់ពេលប៉ុល ពតគេរំលាយអស់ទៅ ពេលដាច់ប៉ុល ពតមកម្ដាយឪពុកបិតនៅក្នុងការបាត់បង់អ្វីៗទាំងអស់នូវអ្វីដែលគាត់ខំរក អ៊ីចឹងពេលធំឡើងធំដឹងក្ដីឡើងយើងដឹងតែពីដឹងនូវភាពអត់ឃ្លានលំបាកយើងបិតនៅក្នុងភាព លំបាកហើយយើងគឺជាកសិករហើយក្នុងកុមារភាពខ្ញុំមានតួនាទីដូចជាឃ្វាលគោ រកស្មៅអោ យគោហើយដើររកកាប់អុសសំរាប់ដុត ហើយនឹងរកត្រីដើម្បីចិញ្ចឹមគ្រួសារហើយនឹងជួយស្ទូង ដកឪពុកម្ដាយជារៀងរាល់ឆ្នាំ!!!មួយឆ្នាំអ៊ីចឹង ពីរមួយឆ្នាំទៅមួយឆ្នំាហើយដល់អ៊ីចឹងហើយ ការងារញ៉ុមវាហាត់វានឿយវាលំបាកណាស់ទទួលភាពក្ដៅភាពរងា ភាពអត់ឃ្លានភាពមិនសំបូរ សប្បាយភាពអត់មានអីស្លៀកពាក់ប៉ុន្តែគ្រាន់តែថាវាអត់មានចេះឈឺអី!!សុខភាពយើងល្អយើង អត់ឈឺ ប៉ុន្តែអាភាពនឿយហាត់ហ្នឹងវាហាត់នឿយហួសពីការស្មាន វាហាត់បំផុតសំរាប់ខ្ញុំពេលខ្ញុំ នៅកុមាររហូតទាល់តែខ្ញុំធំ នៅតែយ៉ាប់ការងារហ្នឹងរហូតទាល់តែចាស់ហ្នឹងបានគ្រាប់បន្តិច!!

ក៖ អ៊ិចឹងលោកពូដូចជាចាប់អាជីពជាគ្រូពេទ្យប្រហែលដូចជាប៉ុន្មានឆ្នាំដែរ?

ខ៖ ប្រហែលជា១៧ ១៨ឆ្នាំហើយ!!

ក៖ ១៧ ១៨ឆ្នាំហើយ?

ខ៖ បាទគ្រាន់តែយើងជួយអើរដល់ប្រជាជននៅក្នុងភូមិរបស់យើងដែលគ្នាមានបញ្ហាត្រូវជួយ សង្គ្រោះបន្ទាន់ ដូចជាជំងឺអីដែលយើងត្រូវជួយពួកគេយើងជាពេទ្យត្រូវជួយពួកគាត់ឬក៏បញ្ជូន ពួកគេទៅមន្ទីរពេទ្យទៅអោយទាន់សភាពការទៅអោយទាន់នឹងគ្រោះថ្នាក់អីអញ្ចឹងទៅ ណាស់!!អញ្ចឹងយើងមិនអាច មិនអាចទៅព្យាបាលជំងឺអីធំដុំបានទេគ្រាន់តែយើងអាចចេះដឹង

ជាពួកគាត់យើងអាចជួយពួកគាត់បានថាត្រូវធ្វើម៉េចអីធ្វើម៉េចអីអញ្ចឹងណាស់!!ហើយអើរអាជួយសង្គ្រោះបឋមហ្នឹងដូចជាវាមានការចាំបាច់ដែរណាស់!!ហ្នឹងហើយ។

ក៖ អរគុណច្រើនលោកពូដែលបានជួយប្រាប់ពីបទពិសោធន៍ការងាររបស់លោកពូ !!អ៊ីចឹងប្រហែលជាអ្វីដែលញ៉ុមចង់ដឹងបន្តទៅទៀតញ៉ុមចង់ដឹងពីប្រវត្តិនៃការរៀបអាពាហ៍ពិពាហ៍របស់លោកពូហាំ អ៊ីចឹងអើលខើរចង់ដឹងថាប្រវត្តិលោកពូយ៉ាងម៉េចដែរលោកពូអាចស្គាល់អ្នកមីងហើយតាមយករៀបការអញ្ចឹង?

ខ៖ សំរាប់ញ៉ុមពួកយើងជាមនុស្សសម័យមុនដោយសារយើងពីដើមយើងអត់បានទំនាក់ទំនងស្នេហាស្គាល់គ្នាអីបានកាន់ចាប់ដៃគ្នា និយាយគ្នាឆ្លើយឆ្លងតាមរយៈទូរសព្ទ័អីគេទេបានមិនមានទេ!!

ក៖ បាទ!!

ខ៖ សំរាប់ក្រុមគ្រួសារប្តីប្រពន្ធរបស់ខ្ញុំខ្ញុំនិយាយគ្នាមុនការមួយម៉ាត់មុនក៏អត់បានផង គ្រាន់តែបានឃើញមុខគ្នាមិនបានញញឹមដាក់គ្នាផង ដល់គេគេនាំអោយយើងទៅមើល យើងឃើញកូនគេអញ្ចឹងយើងត្រលប់ទៅវិញយើងអត់បានទៅនិយាយឆ្លើយឆ្លងសាសងគ្នាភាពជាទំនាក់ទំនងស្នេហាអីអត់មានទេណាស់!!

ក៖បាទ!!

ខ៖ ដោយសារយើងដឹងស្រាប់ហើយដោយសារប្រពៃណីហ្នឹងពេលមុនទេណាស់ មិនមែនដូចជាក្មេងសម័យឥឡូវគេស្គាល់គ្នារួចអស់ហើយ គាត់យល់គ្នាហើយបានគេទំនាក់ទំនងគេហើយបានគេរៀបការ តែខ្ញុំគឺអត់ទេ ទំនាក់ទំនងគ្នាជាប្តីប្រពន្ធហ្នឹងវាដូចជាអត់ដូចជាថាខាងស្រីហ្នឹងអោយតែដឹងថាខាងយើងយល់ព្រម ឃើញគ្នាអ៊ីចឹងហើយម៉ែឪថាយល់ព្រមក៏គាត់ចាប់ផ្តើមរៀបចំថ្ងៃខែរៀបអាពាហ៍ពិពាហ៍អោយយើងទៅ។

ក៖អ៊ីចឹងមានន័យថាការរៀបអាពាហ៍ពិពាហ៍របស់លោកពូគឺត្រូវបានរៀបចំឡើងដោយឪពុកម្តាយទាំងសងខាង?

ខ៖ ហ្នឹងហើយទាំងសងខាង!!

ក៖ អ៊ីចឹងទាំងសងខាងលោកពូណោះ?

ខ៖ ហ្នឹងហើយ។

កៈ អ៊ីចឹងដោយសារប្រពៃណីខ្មែរយើង!!

ខៈ អ៊ីចឹង យើងអត់អាចស្រលាញ់ គេក៏អត់បានថានិយាយរកយើងបានមួយម៉ាត់ដែរ!!

កៈបាទ!!

ខៈដល់ពេលការ ការហើយបានយើងចាប់ផ្ដើមនិយាយរកគ្នាតែម្ដង!!និយាយគ្នាតែម្ដង ថាមានហោ!!ថាដូចជាវាពិបាកដែរ!!អត់បានមួយម៉ាត់ទេ ញ៉ុមមានព្រះញ៉ុមហ៊ាននិយាយ!

កៈបាទ!!

ខៈ ញ៉ុមហ៊ាននិយាយ ញ៉ុមអត់ដែលបានទាក់ទងគ្នាអីបន្តិចសោះ!!

កៈបាទ!!

ខៈនិយាយជាមួយគេសោះគ្រាន់តែបានឃើញគេនៅកន្លែងកាត់ដេរអីអញ្ចឹងទៅណាស់!!

កៈបាទ!!

ខៈ ឃើញគេអញ្ចឹងទៅណាស់!!

កៈ អ៊ីចឹងដូចជាអ្វីដែលលោកពូបានរៀបរាប់ប្រាប់ពត៌មានមកហ្នឹងគឺការរៀបការរបស់លោកពូត្រូវបានរៀបចំឡើងដោយឪពុកម្ដាយទាំងសងខាង អ៊ីចឹងឪពុកម្ដាយទាំងសងខាងក៏ទទួលស្គាល់ដែរ!!អ៊ីចឹងលោកពូចាំពីថ្ងៃរៀបអាពាហ៍ពិពាហ៍ហ្នឹងទេលោកពូ?

ខៈ ឆ្នាំ១៩៩៩ហ្នឹង!!

កៈ ឆ្នាំ១៩៩៩នេះទេ!!ពូចាំខែទេ?

ខៈ ខែអើរខែ០៩ខែផល្គុនខែ០៩ ហោចូលខែផល្គុនខែ០៣ហោមុនចូលឆ្នាំ ដោយសារខែចេត្រខែ០៤ណាស់!!

កៈហ្នឹងហើយ។

ខៈ ហ្នឹងហើយខែ០៤។

កៈបាទអញ្ចឹងពូអាចជួយទាក់ទងនឹងចំលើយហ្នឹងតើមានអោយបណ្ដាការគេបង្គាប់ជាអីដែរ?

ខ៖ ជំនាន់ហ្នឹងគេបង្គាប់ជាមាស ជាមាស!!

ក៖បាទ!!

ខ៖គេមិនមែនបង្គាប់ជាលុយទេ!!បាទហើយជំនាន់ហ្នឹងខាងប្រពន្ធញ៉ុមហ្នឹងគេបង្គាប់ថ្លៃ ថ្លៃគឺ៦ជីមាសហើយថ្លៃណាស់ គេវិញគឺបង្គាប់តែមួយជីពីរជីទេតែចំពោះម្ដាយក្មេកខ្ញុំគេយកថ្លៃគេយកទៅ៦ជី។

ក៖បាទ!!

ខ៖បាទហើយអ៊ីចឹងវាពិបាករកមែនទែនណាស់!!បណ្ដាការគេហើយចំណែកស៊ីសុខខាតចំនេញអីផ្សេងទៀតអាហ្នឹងយើងគ្រាន់តែអោយគេទេ។

ក៖អ៊ីចឹងឡូយមែនទែនពូ!!អ៊ីចឹងប្រហែលជាសំនួរបន្ទាប់ទៀតប្រហែលជាចង់ដឹងខ្លះៗពីប្រវត្តិបទពិសោធន៍ពូតើពូធ្លាប់ទៅក្រៅប្រទេសអីអញ្ចឹងទេពូ?

ខ៖ ទៅហុងកុងហ្នឹង!!

ក៖ កាលហ្នឹងពូទៅជាលក្ខណៈគ្រួសារឬក៏ទៅប៉ុន្មាននាក់ដែរពូ?

ខ៖ទៅ៤នាក់!!

ក៖ទៅឆ្នាំណាដែរពូ?

ខ៖ ឆ្នាំ២០១១។

ក៖ ២០១១ !!អញ្ចឹងពូបានទៅតែហុងកុងហ្នឹងបានតែម្ដងហ្នឹងទេ??

ខ៖ បាទ!!

ក៖ អ៊ីចឹងអើរ អ៊ីចឹងបាននិយាយពីបទពីសោធន៍នៃការងាររបស់ពូអ៊ីចឹងពូអត់ស្វរពីបាកអីណាប៉ុន្មានបន្ទាប់មកពូបានធ្វើពេទ្យរយៈពេល១០ជាងឆ្នាំហ្នឹង?

ខ៖ហ៊ឺ!!

ក៖អញ្ចឹងមួយទៀតពូ ពូបានប្រាប់ថាពូបានកើតនៅជំនាន់៧២(១៩៧២)អ៊ីចឹងពូបានរស់នៅក្នុងជំនាន់ប៉ុល ពតអ៊ីចឹងហាំ!!តើពូអាចជួយចែកចាយបទពិសោធន៍?

ខ៖ សំរាប់ញ៉ុម ញ៉ុមកើតឆ្នាំ៧២(១៩៩៧)ហើយបន្ទាប់មកប៉ុល ពតវ៉ៃដាច់ភ្នំពេញ!!ប៉ុន្តែត្រូវបាន គេជំលៀសប៉ុន្តែគ្រួសារញ៉ុមនៅម្ដុំព្រែកលៀបហើយម្ដាយញ៉ុមបង្ខំចាកចេញមុនគេបែក ភ្នំពេញដោយសារគាត់គិតឃើញថាខ្ញុំកូនភ្លោះ អ៊ីចឹងបើសិនជាគាត់មិនចេញមុនប៉ុលពតចូល ភ្នំពេញទេ គាត់ប្រហែលជាអាចស្លាប់កូនទាំងអស់!!អ៊ីចឹងគាត់តែងតែប្រាប់ឪពុកថាយើងត្រូវ ចេញទៅស្រុកកំណើតវិញទៅអ៊ីចឹងទៅទៅបាត់ដំបងដោយសារមានជីដូនមួយគាត់ធ្វើគ្រូពីរ បី នាក់នៅហ្នឹងហា! ហើយគាត់ចង់អោយម្ដាយញ៉ុមហ្នឹងក៏ទិញសំបុត្រយន្តហោះទៅ ហើយនៅ កាលហ្នឹងគេអត់ទាន់ផ្ដាច់ជើងយន្តហោះទេនៅ ក្នុងហោះក្នុងស្រុកវាបាន ហោះក្រៅស្រុកបាន ម្ដងៗ ទោះវាផ្លោងអីណា ឪពុកញ៉ុមនៅថាអ៊ីចឹងឪពុកញ៉ុមថាអញ្ចឹងយើងកុំទៅស្រុកវិញព្រោះ អីនៅតំបន់យើងកំពង់ចាមព្រៃឈរសុទ្ធតែតំបន់រំដោះហើយតំបន់ខ្មែរក្រហមហើយអ៊ីចឹងយើង ប្រជាជនថ្មីហើយប្រជាជនលន់ នល់ហើយ!!អ៊ីចឹងយើងជាចំណាប់ខ្មាំងរបស់គេហើយ ប៉ុន្តែម្ដា យខ្ញុំគាត់មានបង បងប្អូនធ្វើគ្រូបង្រៀននៅកំពង់ចាម ធ្វើគ្រូបង្រៀនលោកនៅកំពង់ចាមហើយ មានបងប្អូនលោកនៅកំពង់ចាម ហើយមានប្អូនស្រីគាត់នៅកំពង់ចាមដល់អ៊ីចឹងនិយាយអោយ អស់គឺគ្រួសារញ៉ុមជាគ្រួសារដែលចូលចិត្តរៀនហើយនឹងធ្វើការដល់អញ្ចឹងដល់ពេលអញ្ចឹង គាត់សំរេចចិត្តថាគាត់មិនទៅបាត់ដំបងទេ ត្បិតអីម្ដាយហើយនឹងបងប្អូនគាត់ហ្នឹងនៅទីនេះ ទាំងអស់ដល់តែអ៊ីចឹងគាត់ទាញឪពុកញ៉ុមមក មកទៅគេក៏គេយកយើងជាចំណាប់ខ្មាំងមែនគេ បានបញ្ជូនពីភូមិដែលយើងនៅហ្នឹងទៅនៅកន្លែងផ្សេងដោយសារយើងហ្នឹងគេចាត់យើងជា ចំណាប់ខ្មាំងជាមនុស្សមកពីទីក្រុងអញ្ចឹងហាតាមពិតយើងចេញពីស្រុកស្រែទៅដោយសារស ង្គ្រាមទេដោយសារការបាញ់ទំលាក់គ្រាប់បែកអីខ្លាំងពីកងទ័ពសហរដ្ឋអាមេរិចអីអញ្ចឹ ងណាស់!!ហើយយើងប្រជាជាជនដូចជាក្រុមគ្រួសារញ៉ុមអញ្ចឹងអត់គាំទ្រកុំមុយនីសអត់គាំទ្រ របបផ្ដាច់ការ ដូចជាអារបបអាដេញដូចជាយើងកុំមុយនីសហ្នឹងហាំ!!ពួកញ៉ុមហើយនឹងក្រុម គ្រួសារញ៉ុមស្រលាញ់របបសេរី ស្រលាញ់អើរសហរដ្ឋអាមេរិច ស្រលាញ់ច្បាប់ប្រជាធិបតេយ្យ អ៊ីចឹងណាស់ ហើយចូលចិត្តអាមេរិចតាំងពីដើមមកអ៊ីចឹងអើរពួកញ៉ុមអត់ត្រូវបាននៅស្រុកទេ ត្រូវបានគេចាត់ទុកជាចំណាប់ខ្មាំងហើយក៏គេជំលៀសពួកខ្ញុំទៅនៅភូមិផ្សេងប៉ុន្តែបានឪពុកធំ ខ្ញុំចេះតែជួយនិយាយជាមួយសាម៉ាក់មិត្ត សាម៉ាក់មិត្តអ្នកធំអ្នកធំហ្នឹងដើម្បីអោយគេយល់ យោគអីអញ្ចឹងណាស់ថាគ្នាចេញទៅថាគ្នានៅមិនបានដោយសារសង្គ្រាមអីវ៉ាន់អញ្ចឹងទេ អញ្ចឹ ងទៅគេក៏អោយយើងមករស់នៅហ្នឹងវិញ ប៉ុន្តែនៅក្នុងការរស់នៅពីឆ្នាំ៧៥(១៩៧៥)៧៩ (១៩៧៩)៣ឆ្នាំ៨ខែ នឹង២០ថ្ងៃហ្នឹងទុកសោករបស់ពួកខ្ញុំគឺទុកសោកហួសពីការស្មាន ដោយសារគេចាត់ទុកពួកខ្ញុំហ្នឹងជាខ្មាំងអ៊ីចឹងមនុស្សដែលគេចាត់ទុកជាសត្រូវរបស់គេគេមិន ដែលអោយយើងស៊ីស្រួលរស់ស្រួលទេ អ៊ីចឹងទារុណកម្មសព្វទៅលើគ្រួសារខ្ញុំ ទីបំផុតត្រូវបាន ធ្វើអោយគ្រួសារញ៉ុមស្លាប់ទាំងអស់ ស្លាប់ទាំងយាយស្លាប់ទាំងតា ស្លាប់ទាំងឪពុកមា ស្លាប់ ទាំងម្ដាយមីង ជីដូនមួយរបស់ខ្ញុំទាំងអស់គឺថាមួយពូជត្រូវគេសម្លាប់ចោលទាំងអស់ សូម្បីតែ

ម្នាក់នៅសល់តែម្តាយរបស់ខ្ញុំហើយនឹងឪពុករបស់ខ្ញុំហើយនឹងបងប្អូន៦នាក់ហ្នឹងតែប៉ុណ្ណឹង មួយគ្រួសារហើយក្រៅពីហ្នឹងត្រូវបានគេយកទៅសម្លាប់ចោលទាំងអស់ ហើយមួយហ្នឹងវាធ្វើ អោយពួកខ្ញុំដឹងក្តីឡើងមានភាពតក់ស្លុតក្នុងចិត្តថាដោយសារអ្វីទាំងអស់ហ្នឹងអោយមានវិបិត្ត ក្នុងចិត្តហ្នឹងហើយហើយគេបង្អត់យើងសព្វបែបសព្វយ៉ាងហើយខ្ញុំនៅក្មេងអាយុ៨ឆ្នាំហ្នំណាស់ ហើយអត់មានអីហូបហើយព្រលឹមឡើងដើររើសត្រីក្រោមផ្ទះគេ កាយ ជួនកាលបានយកក្តាម យកមកស៊ីឆៅក៏មានហើយកូនកង្កែបនៅក្នុងទឹកហ្នឹងនៅឆៅហ្នឹងមានភ្លើងហ្នឹងវារាងក្តៅៗដាក់ អោយតែរីងៗហ្នឹងយកមកហែងស៊ីដូចសត្វ ដូចសត្វតិរច្ឆាន ដូចសត្វនរកអ៊ីចឹង ហើយខ្លួនកាយ រាងកាយហ្នឹងស្គាំងស្គមមិនដែលបានអីស្គាល់រសជាតិអី ហើយឃើញដូងគេបោះចោលនៅ តាមថ្នល់ហ្នឹង លលា លលាហ្នឹងកកេកកាយស៊ីហើយគឺថាដឹងមកគឺថាដឹងតែវេទនាអ៊ីចឹងម៉ង ហើយវា ហើយភាពតស៊ូ៣ឆ្នាំ៨ខែហ្នឹង វាសឹងតែមួយសម័យហ្នឹងវាស្លាប់ច្រើនមែនទែន តែ ចំពោះខ្ញុំម្តាយខ្ញុំថាមានតែស្បែកហើយនឹងឆ្អឹងតែអត់ឈឺ បើសិនជាឈឺស្លាប់ទាំងអស់ប្អូន កូន គាត់នោះណាស់តែខ្ញុំដូចជាមានពរជ័យពីព្រះដែរ ដែលព្រះទុកជីវិតអោយពួកខ្ញុំនៅណាស់ ខ្ញុំ ដឹងថាអញ្ចឹងណាស់ ហើយខ្ញុំឆ្លងកាត់របបហ្នឹងឆ្អែតឆ្អន់ហើយទីបំផុតវាបានរួចផុតពីសេចក្តី ស្លាប់ក្រៅពីពួកគេបានស្លាប់ចោលពួកខ្ញុំទាំងអស់ទៅ ហើយក៏ដាច់៧៩(១៩៧៩)មកហ្នឹង ហើយផុតពីអាពតហើយ  តែនៅសម័យហ្នឹងវាពិបាក នៅក្នុងសម័យហ្នឹង សូម្បីតែមួយថ្ងៃបាន បានបបរ គេចែកអោយបានមួយវែកក្បាលស្វាហ្នឹងស្និតទៅបានអង្ករតែមួយស្លាបព្រាគត់ ហើយពេលខែវស្សាគេអោយយើងស៊ីតែដំឡូងមួយដុំទេ ក្នុងមួយពេលហើយញ៉ុមឃ្លាំងមែន ទែនដោយសារញ៉ុមឃ្លានហើយមិនដឹងថាបានអីមក ហើយជួនកាលមានម៉ោង១២យប់អីអញ្ចឹ ងមានម្តាយមានឪពុកមកជួនកាលគាត់មកជួបកូនឃើញឡើងបើកទ្វារមកអើតកូនមកមាន ជួនកាលគាស់គល់ចេក អាគល់ចេកឡើងៗហ្នឹងយកមកស្ងោរ ជួនកាលគល់ល្ហុងស្ងោរទៅ ដាស់កូនអោយហូប ជួនកាលបានពីណាមកស្បែកក្របីយកមកត្រាំទឹកទៅដាក់ដាំដាក់ដុតទៅ ដំទៅអោយកូននៅអង្គែមទាំងយប់ហ្នឹង ហើយយើងក្មេងអាណាងងុយដេកចង់ងាប់ទៅ ទៅ អង្គែមឯណាអើរពួកគាត់ដាស់យើងអោយស៊ីហើយពួកគាត់មានពេលជួបយើងតែពេលយប់ទេ ថ្ងៃពួកគាត់អត់មានពេលជួបយើងទេអ៊ីចឹងភាពរស់នៅភាពកក់ក្តៅពីឪពុកម្តាយហើយនឹងខ្ញុំវា សឹងថាមិនបានជួបគ្នាដល់ចប់ចុងចប់ដើមទៅណាស់!!វាមិនដូចយើង ដូចយើងចិញ្ចឹមកូនសព្វ ថ្ងៃវាមានភាពកក់ក្តៅហួសពីអ្វីដែលញ៉ុមរស់នៅ អញ្ចឹងបានថាភាពរស់នៅរបស់ខ្ញុំវាពិបាក ហួសប្រមាណ វាមិនើនឹងស្មានជីវិតញ៉ុមរស់នៅដល់សព្វថ្ងៃដោយសារវាលំបាកសព្វគ្រប់ សភាពការទាំងអស់ប៉ុន្តែសុខភាពវាអត់ឈឺប៉ុណ្ណឹងហាំ វាស្គមប៉ុណ្ណាក៏ដោយវាអស់សាច់ប៉ុណ្ណា ក៏ដោយក៏វាមិនឈឺ បើសិនជាវាឈឺវាអាចស្លាប់មែនអញ្ចឹងខ្ញុំក៏តស៊ូមករហូតរហូតទាល់តែដាច់ ពីអាពតហ្នឹងទៅក៏បានចូលរៀនចូលសូត្រអីទៅ ក៏បានរស់រានដល់សព្វថ្ងៃហ្នឹងទៅ ។

ក៖ អ៊ីចឹងថានៅជំនាន់ប៉ុល ពតហ្នឹងពូរស់នៅជាមួយនឹងអ្នកណាគេដែរ?

ខ៖ គឺខ្ញុំមានអ្នករស់នៅជាមួយខ្ញុំគឺខ្ញុំមានបងប្អូន៦នាក់ បងខ្ញុំបង្អស់ហ្នឹងគេធ្វើចល័តហើយ គេធ្វើចលត័ហើយប្រហែលជាប៉ិនអ៊ែលឌើរឯងហ្នឹង គេធ្វើចល័តមក គេត្រូវបានចាត់អោយធ្វើជាទាហានបាញ់ទៅបាញ់កងទ័ពវៀតណាមនៅឯព្រំដែនខាងកើត ហ្នឹងហើយប៉ុនៗអ៊ែលឌើរឯងហ្នឹងគេអោយទៅធ្វើទាហានទាំងអស់ហើយអត់មានបានអ្នកណាគេវិលមកវិញគឺត្រូវបានស្លាប់ទាំងអស់គឺត្រូវទាហានវៀតណាមបាញ់សំលាប់ចោលទាំងអស់ហើយនៅបានបងញ៉ុមរស់មកវិញ!! ចំនែកបងញ៉ុមទីពីរស្លាប់ដោយសារឆ្កែខាំ តែបើបងញ៉ុមទី៣គេធ្វើជាឆ្លប ហាគេធ្វើដេញជាអើរកងកុមារហ៊ីដូចជាជួយដើរធ្វើស្រែជាមួយមនុស្សចាស់អីដែរអញ្ចឹងណាស់!!ចំនែកខ្ញុំ ខ្ញុំនៅផ្ទះ ហើយមើលប្អូន ប្អូនកើតឆ្នាំ៧៥(១៩៧៥)មួយអត់មានពីណាមួយជួយមើលប្អូនបន្ទាប់មកគេក៏យកប្អូនញ៉ុមហ្នឹងចេញពីពួកខ្ញុំយកទៅអោយមនុស្សចាស់មើលហើយញ៉ុមក៏រស់នៅតែពីរនាក់បងប្អូនទេ!!បានអ្នកគ្រូទូចខ្ញុំហើយប្អូនស្រីញ៉ុមហ្នឹងដោយសារពួកញ៉ុមនឹងភ្លោះណាស់!!

ក៖បាទ!!

ខ៖ ញ៉ុមរស់នៅតែពីរនាក់ហ្នឹងហើយទាំងយប់ទាំងថ្ងៃហើយជួនកាលអត់ទាន់បានឃើញមុខម៉ែម្តងទេដល់ជួនកាលម្តាយញ៉ុមយកញ៉ុមដើរតាម ដើរគាត់យកញ៉ុមទៅកន្លែងគាត់ធ្វើការហាំ!! គេអាចអោយបាយយើងឆ្អែតជួនកាលគេអោយយើងបានលើកអីអញ្ចឹង ជួនកាលក៏កងគេគេតិចទៀននឹងម្តាយខ្ញុំថាយកក្មេងមករកធ្វើអី ទុកនៅហ្នឹងរោងបាយទុកនៅនឹងអី វាមានរបបដែរនឹងហើយហើយក៏មានគេខ្លះគេអានិតម៉ែញ៉ុមទៅញ៉ុមលឺសំលេងហ្នឹងហាំ !! ហ្ហ៊ូវាស៊ីប៉ុន្មានទៅក្មេងហ្ហ៊ូអោយវាមួយឆ្អែតទៅ ថាអញ្ចឹងហាំ!! គាត់យកទៅយកទៅខ្ញុំបានស៊ីបានឆ្អែតគេអោយគេអោយមួយវែកអីអញ្ចឹងទៅយើងក្មេងអញ្ចឹងណាស់ បើនៅផ្ទះយើងអត់បានអីគេស៊ីទេ!!វាអត់បានអីគេស៊ីសោះអញ្ចឹងយើងត្រូវដើរតាមគាត់ហ្នឹងអញ្ចឹងទៅ!!ហ្នឹងហើយប៉ុន្តែបើធាតុពិតទៅមិនសូវបានរស់នៅជាមួយឪពុកម្តាយប៉ុន្មានទេ!!ហើយមិនដែលបានស្គាល់ពាក្យអប់រំពីម៉ែពីឪទទួលបានភាពកក់ក្តៅពីម៉ែពីឪទេ គឺរស់នៅដូចសត្វដូចធាតុអញ្ចឹង ហ្នឹងហើយរស់នៅហ្នឹងមិនស្មើនឹងសត្វផង បើសត្វរាល់ថ្ងៃគេថៃទាំគេងូតទឹកណាស់!!ចាក់ថ្នាំគេមើល ក្មេងសម័យប៉ុល ពតហាំវាមិនស្មើនឹងសត្វតិរិច្ឆានសព្វថ្ងៃផង សត្វសព្វថ្ងៃគេមានកន្ទួកស៊ីវាមានអីស៊ី មនុស្សវាររកកន្ទួកស៊ីមិនបានផងហ្នឹងហើយមនុស្សអាចមន៍អាចមន៍សត្វជើងដើរទៅជុះសុទ្ធតែជើងមនុស្សប៉ុន្តែអាចមន៍សុទ្ធតែអាចមន៍សត្វមិនមែនអាចមន៍មនុស្សទេអាហ្នឹងមានន័យថាមនុស្សរស់នៅគ្មានចំនីមនុស្សស៊ីទេ ហ្នឹងហើយស៊ីតែចំនីសត្វស៊ីតែអាហារសត្វអ៊ីចឹងវាអាណោចអាធម្មខ្លាំងមែនទេ ។

ក៖ អញ្ចឹងអរគុណច្រើនមែនទែនលោកពូដែលបានចែកចាយបទពិសោធន៍កាលពីជំនាន់!!

ខ៖បាទ!!

ក៖របបប៉ុល ពតហ្នឹង!!

ខ៖ ហ្នឹងហើយ បាទ!!

ក៖អញ្ចឹងប្រហែលជាសំនួរបន្ទាប់ដូចជាអ្វីដែរពូបាន ដូចជាញ៉ុមចង់សួរហើយចង់អោយលោកពូចែកចាយពេលវេលាដ៏ល្អមួយដែលល្អបំផុតនៅក្នុងជីវិតរបស់លោកពូហាំដែលធ្វើអោយលោកពូសប្បាយចិត្តហើយធ្វើអោយលោកពូចងចាំរហូតមកដល់សព្វថ្ងៃអ៊ីចឹងលោកពូអាចជួយទាក់ទងចែកចាយអំពីអ្វីដែលលោកពូបានរៀនហ្នឹងហាំពូ?

ខ៖ គឺពេលវេលាម៉េច?

ក៖ ពេលវេលាដែលល្អដែលធ្វើអោយលោកពូសប្បាយចិត្តក្នុងជីវិតអញ្ចឹងហាំ?

ខ៖ ពេលវេលាដែលល្អសំរាប់ជីវិតរបស់ខ្ញុំមាន ខ្ញុំមានតាមឋានៈតាមកាលៈទេសៈអ្វីដែលខ្ញុំមកដល់អាយុប៉ុណ្ណេះគឺពេលដែលខ្ញុំបានស្គាល់អំពីដំណឹងល្អ!!

ក៖បាទ!!

ខ៖គឺនៅពេលដែលខ្ញុំស្គាល់អំពីផ្លូវរបស់ព្រះទើបខ្ញុំដឹងថាពេលវេលាមួយហ្នឹងធ្វើអោយគ្រួសារខ្ញុំទទួលបានពរជ័យដ៏ធំរីករាយបំផុត ទោះថាញ៉ុមមិនមានឡានមិនមានវិឡា មិនមានលុយកាកអីច្រើនសំរាប់គ្រួសារខ្ញុំតែដូចថាព្រះរៀបចំគ្រួសារខ្ញុំអោយរស់នៅដោយបានភាពសុខសាន្តណាស់!!អើរខុសប្លែកពីពេលដែលញ៉ុមអត់ទាន់បានស្គាល់ដំណឹងល្អ ដោយសារយើងស្គាល់ពីផ្លូវរបស់ព្រះគឺយើងស្គាល់ខុសពីផ្លូវដទៃ គឺយើងចេះអើរចេះយល់ចិត្តគ្នា អត់អភ័យទោសអោយគ្នា ពេលអត់ ចេះអត់ធ្មត់ក្នុងការអត់ឃ្លាន ហើយចេះអត់ធ្មត់អធ្យាស្រ័យដល់អ្នកដទៃហើយចេះធ្វើអោយយើងចេះស្រលាញ់កូនច្រើនហើយផ្តល់កំលាំងចិត្តទឹកចិត្តអោយកូនបើនិយាយទៅគឺថាពេលដែកបានស្គាល់ហ្នឹងគឺព្រះបានបង្រៀនយើងបានច្រើនមែនទែនហើយដើម្បីអោយយើងចងចាំពេលវេលានេះគឺជាពេលវេលាមួយដ៏អស្ចារ្យសំរាប់ក្រុមគ្រួសាររបស់ខ្ញុំហាំ!! បាទ!!

ក៖ អរគុណពូ អ៊ីចឹងការពិតញ៉ុមភ្លេចបានសួរលោកពូទាក់ទងទៅនឹងរបបប៉ុល ពតអញ្ចឹងហាំអញ្ចឹងពូអាចជួយរៀបរាប់ឈ្មោះទាំង៦នាក់ដែលពូឈ្មោះគាត់ហាំបានទេពូ?

ខ៖ ហ៊ើបងខ្ញុំទីមួយឈ្មោះគឺ កូវ ដារ៉ា បងស្រីទីពីរឈ្មោះកូវ នារី ហើយបងប្រុសទីបីឈ្មោះកូវ ដារិទ្ធ ហើយបន្ទាប់មកខ្ញុំឈ្មោះកូវ វ៉េងឌី!!

ក៖បាទ!!

ខ៖ ហើយបន្ទាប់មកគឺកូវ ស្រីទូច!!

ក៖បាទ!!

ខ៖ ហើយបន្ទាប់មកទៀតកូវ វឌ្ឍន: ហើយបន្ទាប់មកទៀតគឺកូវ ស៊ីវ៉ាត!!

ក៖បាទ!!

ខ៖ បាទ ៧នាក់ស្លាប់មួយសល់៦។

ក៖៦នាក់។

ខ៖ រាល់ថ្ងៃ!!

ក៖ អញ្ចឹងឥឡូវតើពួកគាត់រស់នៅឯណាដែរពូ?

ខ៖អើរាល់ថ្ងៃពួកគាត់មានប្រពន្ធបែកនៅឆ្ងាយៗពីគ្នា នៅក្នុងភូមិរបស់ម្ដាយខ្ញុំហ្នឹង៣នាក់ ហើយគាត់ទៅរស់នៅខាងស្រុកស្ទឹងត្រង់ ស្រុកខាងសម្ដេចហ៊ុនសែនហ្នឹង២នាក់!!

ក៖បាទ!!

ខ៖ ហើយចំពោះខ្ញុំហ្នឹងនៅភូមិខុសគ្នាតែនៅឃុំជាមួយគ្នានៅជាមួយបងប្អូនហ្នឹង៣នាក់ហ្នឹងដែរ!!អញ្ចឹងទៅណាស់ ហ្នឹតងហើយ ហ្នឹងហើយ ដោយសារញ៉ុមនៅភូមិអំពិលធំ បងប្អូនញ៉ុម៣នាក់ទៀតនៅភូមិព្រះធាតុប៉ុន្តែឃុំឃុំខ្វិតស្រុកព្រៃឈរដូចតែគ្នាណាស់!!

ក៖បាទ!!

ខ៖ ក៏ប៉ុន្តែប្រុសៗពីរនាក់ទៀតគាត់ទៅនៅខាងស្រុកស្ទឹងត្រង់ហ្នុំ!!

ក៖បាទ!!

ខ៖ ហ្នឹងហើយគេមានប្រពន្ធនៅហ្នឹង!!

កៈ អញ្ចឹងមិញពូ ពូប្រាប់ថាពូមានបងប្អូនភ្លោះទៀត?

ខៈ បាទខ្ញុំភ្លោះ!!

កៈមែន??

ខៈ បាទ!!គាត់ជាសមាជិកដែរតែឥឡូវគាត់អសកម្ម!!

កៈមែន?

ខៈ បាទ!!

កៈ ភ្លោះ ភ្លោះទាំងប្រុសពីរឬក៏ភ្លោះប្រុសមួយស្រីមួយ?

ខៈ ស្រីមួយប្រុសមួយ!!

កៈមែន?

ខៈបាទ!!ហើយសព្វថ្ងៃគាត់ធ្វើគ្រូបង្រៀននៅសាលាបឋមសិក្សាល្វាហ្នឹងហាំនៅព្រៃឈរ!! បាទ!!

កៈ ញ៉ុមអត់ដឹងសោះ!!

ខៈ បាទ!!កូនភ្លោះជាមួយខ្ញុំ!!

កៈ អូយឡូយមែនទែនលោកពូ!!

ខៈ ស្រីមួយប្រុសមួយ!!

កៈ បាទ!!អញ្ចឹងញ៉ុមពិតជាមានអំណរគុណខ្លាំងមែនទែនដែលពូបានចែកចាយបទពិសោធន៍ជាមួយលោកពូបានរៀបរាប់នូវការរស់នៅនៅជំនាន់ប៉ុល ពតដូចគ្នាហើយនឹងញ៉ុមអង្គុយស្តាប់ពីប្រវត្តិរបស់លោកពូបានខ្លះៗញ៉ុមដឹងថាកិច្ចការមួយនេះវានឹងជាឯកសារមួយទុកជារៀងរហូតវាអត់ងាយបាត់បង់ទេលោកពូ ហើយវាជាឯកសារមួយដើម្បីជួយប្រាប់ដល់កូនចៅលោកពូនៅជំនាន់ក្រោយទៀតពីឆាកជីវិតរបស់លោកពូការឆ្លងនូវទុក្ខលំបាកជាច្រើនទាំងឡាយដែលលោកពូបានមាននៅក្នុងជីវិតសព្វថ្ងៃហ្នឹងទំរាំមកដល់សព្វថ្ងៃហ្នឹងទំរាំបានដែលលោកពូឆ្លងកាត់ពុះពារអ្វីខ្លះអ៊ីចឹងវាជាពង្សប្រវត្តិសំរាប់មនុស្សរស់មួយដែលថាផ្តល់ពរជ័យសំរាប់ទៅដល់ក្រុមគ្រួសារលោកពូមែនទែន អញ្ចឹងបន្ទាប់ពីការចប់សំភាសន៍ហ្នឹងដោយសារខ្ញុំសំភាសន៍

ចប់ខ្សែសំលេងហ្នឹងត្រូវបានអាប់លូតចូលទៅក្នុងវេបសាយរបស់សាលាប៊ី វ៉ាយ យូខាង សាសនាចក្រហាំ!!អ៊ីចឹងតើលោកពូអាចយល់ព្រមដើម្បីអោយពួកខ្ញុំអាចដាក់នៅក្នុងវេបសាយក្នុងហ្នឹងបានទេលោកពូ?

ខ៖ ហ្នឹងហើយយកទៅណាទៅទៅ!!មានអីអត់បញ្ហាអីគេទេបាទ!!

កះបាទអញ្ចឹងញ៉ុមសូមអរគុណសំរាប់ការសំភាសន៍នៅក្នុងថ្ងៃហ្នឹងហាលោកពូ!!

ខ៖ បាទ។